**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០១.....សហវ.-ឧហ

លិខិតចូល

ថ្ងៃទី២៧...ខែកុម្ភៈ...ឆ្នាំ2010

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែកុម្ភៈឆ្នាំ ២០១០

## សេចក្តីជូនដំណឹង

## ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ លោក លោកស្រី ដែលកំពុង ឬមានបំណងប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់អោយបានជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់អោយអនុវត្តប្រកាស លេខ ០២៨ សហវប្រក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ។

ចាប់ពីពេលផ្សាយដំណឹងនេះតទៅ លោក លោកស្រី ទាំងអស់ដែលបាននិងកំពុង ឬមានបំណងប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា **សូមប្រញាប់មកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្ម នៅការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០១០** ។ ផុតកាលវសានេះ ក្រសួងនឹងចាត់វិធានការដាក់ពិន័យតាមខ្លឹមសារដូចមានចែងក្នុងប្រកាសខាងលើ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***<u>ទូរស័ព្ទទំនាក់ទំនង</u>***

- ***០៨៩ ៣៨៨ ៨៨៩***
- ***០១៧ ៩៩៣ ៣៦៨***
- ***០១៦ ៥៥៨ ៥៦៨***
- ***០៦៨ ៨៨៨ ៨៦៤***